ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
អគ្គលេខាធិការដ្ឋាន
លេខ ១០៩ របក អ.ជ.ប.គ.ញ.

ថ្ងៃព្រហស្បតិ៍ ១៥រោច ខែទុតិយាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែ សីហា ឆ្នាំ២០២៦

# របាយការណ៍
## ស្ដីពី
## លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខែកក្កដា និងលើកទិសដៅការងារខែសីហា ឆ្នាំ២០២៦

(ថ្ងៃទី១ ដល់ថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០២៦)

អនុវត្តតាមទិសដៅការងារដែលបានដាក់ចេញ កាលពីខែមិថុនា ឆ្នាំ២០២៦ កន្លងទៅអគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន (អ.ជ.ប.គ.ញ.) ក្នុងនាមជាសេនាធិការ បានសម្របសម្រួល ប្រមូលផ្ដុំដឹកនាំ និងអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ដោយយកចិត្តទុកដាក់និងទទួលខុសត្រូវខ្ពស់ រហូតសម្រេចបានលទ្ធផលដូចខាងក្រោម៖

## I. សភាពការណ៍គ្រឿងញៀន

ក្នុងខែកក្កដា ឆ្នាំ២០២៦នេះ ស្ថានភាពនៃបទល្មើសគ្រឿងញៀននៅតែបន្តប្រែប្រួលស្មុគស្មាញ ដោយក្រុមឧក្រិដ្ឋជនគ្រឿងញៀននៅតែបន្តធ្វើសកម្មភាពចរាចរ ដឹកជញ្ជូន ជួញដូរនិងលួចលាក់កែច្នៃគ្រឿងញៀន ក្នុងនោះ បទល្មើសគ្រឿងញៀនធំៗចាប់ពី ១គីឡូក្រាមឡើង ដែលសមត្ថកិច្ចបង្ក្រាបបាន រួមមានបទល្មើសកែច្នៃនូវសារធាតុញៀន ១ករណី នៅខេត្តស្វាយរៀង ចាប់យកគ្រឿងញៀន **២គីឡូក្រាម** ឃាត់ខ្លួនជនសង្ស័យ ៣នាក់ បទល្មើសដឹកជញ្ជូន និងជួញដូរសារធាតុញៀនឆ្លងដែនពីកម្ពុជាទៅឧបែ ១ករណី នៅខេត្តកណ្ដាល ចាប់យកសារធាតុញៀន(កញ្ឆាក្រៀម) **១១គីឡូក្រាម** ឃាត់ខ្លួនជនសង្ស័យ ៣នាក់។ ជាមួយនោះ បទល្មើសរក្សាទុក ដឹកជញ្ជូន និងជួញដូរនូវគ្រឿងញៀនក្នុងផ្ទៃប្រទេស ៦ករណី នៅរាជធានីភ្នំពេញ ខេត្តស្វាយរៀង តាកែវ កំពង់ចាម ស្ទឹងត្រែង និងខេត្តព្រះសីហនុ ចាប់យកគ្រឿងញៀន **៥០គីឡូក្រាម** ឃាត់ខ្លួនជនសង្ស័យ ២៨នាក់។

**ការកត់សម្គាល់** ក្រៅពីស្ថានភាពនៃបទល្មើសគ្រឿងញៀនខាងលើ ការអនុវត្តផែនការយុទ្ធសាស្ត្រ និងយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ លើកទី១១ សម្រេចបានលទ្ធផលវិជ្ជមានជាច្រើន។ ក្នុងនោះ ការងារផ្សព្វផ្សាយអប់រំត្រូវបានធ្វើឡើងជាប្រចាំ អមដោយការងារព្យាបាល និងស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀនកាន់តែមានប្រសិទ្ធភាព។ ទន្ទឹមនេះ វិធានការរដ្ឋបាលនិងច្បាប់ ត្រូវបានអនុវត្តយ៉ាងសកម្មតាមក្លឹបកម្សាន្ត និងទីតាំងសប្បាយដ្ឋាន តាមរយៈការធ្វើកិច្ចសន្យាហាមឃាត់ការជួញដូរ និងប្រើប្រាស់គ្រឿងញៀន។ បន្ថែមលើនេះ កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជិតខាង ក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍ ក៏ត្រូវបានពង្រឹង និងពង្រីកជាបន្តបន្ទាប់ តាមរយៈការផ្លាស់ប្ដូរព័ត៌មាន បទពិសោធ និងការបណ្ដុះបណ្ដាលរួមគ្នា។



អគ្គលេខាធិការដ្ឋាន នៃ អ.ជ.ប.គ.ញ. មានទីតាំងនៅក្នុងបរិវេណទីស្ដីការក្រសួងមហាផ្ទៃ, Phone : (855) 23 721 648, (855) 16 721 648, P.O.Box: 151
E-mail: info@nacd.gov.kh Website: www.nacd.gov.kh

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន

### ១. ការផ្សព្វផ្សាយអប់រំ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

ការងារផ្សព្វផ្សាយអប់រំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន នៅតាមប្រព័ន្ធផ្សព្វផ្សាយ និងតាមសហគមន៍ ទទួលបានលទ្ធផលដូចខាងក្រោម៖

#### ១.១. ការងារផ្សព្វផ្សាយអប់រំតាមប្រព័ន្ធផ្សព្វផ្សាយ

បានសម្របសម្រួលនិងអនុវត្តសកម្មភាពការងារផ្សព្វផ្សាយអប់រំនៅតាមប្រព័ន្ធផ្សព្វផ្សាយដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- តាមរយៈគេហទំព័ររបស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. (www.nacd.gov.kh) មានការចូលអានចំនួន **១៩១.២៣៤ដង** (កើនឡើង ៥០.៥០៧ដង ស្មើនឹង **៣៥,៩%**) បើធៀបនឹងខែមិថុនា មានចំនួន ១៤.០៧២៧ដង.
- ផ្សព្វផ្សាយអប់រំតាមរយៈឃ្លីបវីដេអូខ្លីៗ តាមបណ្តាញទំនាក់ទំនងសង្គម Facebook Page និងកម្មវិធីទូរស័ព្ទដៃ NoDrug របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- ឆ្លើយតបចម្ងល់មហាជននៅក្នុងFacebook និងPage របស់អគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.ញ. ពាក់ព័ន្ធចម្ងល់ផ្សេងៗ ស្តីពីបញ្ហាគ្រឿងញៀន
- សហការសម្របសម្រួលជាមួយស្ថានីយ៍ទូរទស្សន៍ វិទ្យុ និងបណ្តាញព័ត៌មាន ដើម្បីធ្វើការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន។

#### ១.២. ការងារផ្សព្វផ្សាយអប់រំតាមសហគមន៍

បានសហការសម្របសម្រួលនិងអនុវត្តសកម្មភាពការងារផ្សព្វផ្សាយអប់រំនៅតាមសហគមន៍ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តកណ្តាល រៀបចំពិធីប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា និងដុតបំផ្លាញគ្រឿងញៀន ក្រោមអធិបតីភាព **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅស្រុកពញាឮ ក្រោមប្រធានបទ **«រួមគ្នាឆ្លើយតបបញ្ហាគ្រឿងញៀនក្នុងបរិបទថ្មីប្រកបដោយភាពច្នៃប្រឌិត»**
- ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី៣ របស់ក្រុមការងារអប់រំបង្ការ នៃយន្តការប្រទេសហត្ថលេខីអនុស្សរណៈនៃការយោគយល់គ្នាឆ្នាំ១៩៩៣ (Mekong MOU) នៅប្រទេសចិន
- សហការជាមួយក្រុមប្រឹក្សាបណ្តាញព្រះវិហារគ្រីស្ទបរិស័ទកម្ពុជា ចុះពិនិត្យ និងបន្តអនុវត្តកម្មវិធីគ្រួសាររឹងមាំ(Strong Family) ដំណាក់កាលទី២ នៅខេត្តព្រះសីហនុ
- ជួបពិភាក្សាជាមួយតំណាងសាកលវិទ្យាល័យការពារជាតិ អំពីសៀវភៅគោល ស្តីពីបញ្ហាគ្រឿងញៀន នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.
- សហការជាមួយក្រសួងទេសចរណ៍រៀបចំសិក្ខាសាលាផ្សព្វផ្សាយអប់រំស្តីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀននិងជំរុញApp NoDrug ដល់ប្រតិបត្តិករនិងបុគ្គលិកបម្រើការនៅតាមមូលដ្ឋានអាជីវកម្មសេវាកម្មទេសចរណ៍ នៅខេត្តកណ្តាល
- សហការជាមួយក្រសួងទេសចរណ៍រៀបចំកម្មវិធីផ្សព្វផ្សាយស្តីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន និងជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug ក្នុងវេទិកានិងកម្មវិធីពិព័រណ៍ទេសចរណ៍មូស្លីមកម្ពុជាឆ្នាំ២០២៦ នៅរាជធានីភ្នំពេញ

- ចូលរួមធ្វើបទឧទ្ទេសនាម ស្ដីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ជូនដល់និស្សិត នៃវិទ្យាស្ថានវិទ្យាសាស្ត្រសុខាភិបាលកងយោធពលខេមរភូមិន្ទ នៅរាជធានីភ្នំពេញ

- ចូលរួមផ្សព្វផ្សាយអប់រំ ស្ដីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងកម្មវិធីចុះពង្រឹងការទប់ស្កាត់បទល្មើសគ្រឿងញៀននៅមណ្ឌលអប់រំកែប្រែទី៣ នៅខេត្តត្បូងឃ្មុំ

- ចូលរួមកិច្ចប្រជុំការងារអប់រំបង្ការ ទប់ស្កាត់បញ្ហាគ្រឿងញៀនអាស៊ានលើកទី៣២ ដែលប្រទេសឥណ្ឌូនេស៊ីធ្វើជាម្ចាស់ផ្ទះ តាមប្រព័ន្ធអនឡាញ

- រៀបចំកិច្ចប្រជុំភាគីពាក់ព័ន្ធថ្នាក់ជាតិ ស្ដីពីការបង្ការនិងការអប់រំ អំពីការប្រើប្រាស់គ្រឿងញៀននៅកម្ពុជា នៅទីស្ដីការក្រសួងមហាផ្ទៃ

- សហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រៀបចំការផ្សព្វផ្សាយ ស្ដីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ព្រមទាំងការប្រកួតវោហាកោសល្យក្នុងចំណោមនិស្សិតនិងសាស្ត្រាចារ្យ នៃវិទ្យាស្ថានជាតិកសិកម្មកំពង់ចាម និងជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug នៅខេត្តកំពង់ចាម

- រៀបចំកិច្ចប្រជុំពិនិត្យវឌ្ឍនភាព ស្ថានភាព ការផ្សព្វផ្សាយសកម្មភាព និងព្រឹត្តិការណ៍នានាលើទំព័រប្រព័ន្ធបណ្ដាញសង្គមរបស់អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. នៅអគ្គលេខាធិការដ្ឋាននៃអ.ជ.ប.គ.ញ.

- សហការជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនខេត្តចំនួន១៥ រៀបចំពិធីប្រារព្ធទិវាអន្តរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ថ្ងៃទី២៦ ខែមិថុនា ក្រោមប្រធានបទ« **«រួមគ្នាឆ្លើយតបញ្ហាគ្រឿងញៀន ក្នុងបរិបទថ្មីប្រកបដោយភាពច្នៃប្រឌិត»** និងដុតបំផ្លាញគ្រឿងញៀនដែលមានអ្នកចូលរួមសរុប **១៣.៤២០នាក់**

- សម្របសម្រួលជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ជួយបំផុសជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរសព្ទដៃ NoDrug ក្នុងវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់របស់ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំពីបញ្ហាគ្រឿងញៀនបានចំនួន **១៨.៣៨៨លើក** (ថយចុះ ៩៩៦លើក ស្មើនឹង ៥,១៣%) បើធៀបនឹងខែមិថុនា មានចំនួន ១៩.៣៨៤លើក ដោយគ្របដណ្ដប់លើអ្នកមកទទួលយកសារ **១.០១០.៧៣០នាក់** ស្រី ៥៩១.២៤៦នាក់ (ថយចុះ ៤៨.១៩៨នាក់ ស្មើនឹង **៤,៥៥%**) បើធៀបនឹងខែមិថុនា មានចំនួន ១.០៥៨.៩២៨នាក់

- បំផុស ផ្សព្វផ្សាយ ជំរុញការទាញយកនិងប្រើប្រាស់នូវកម្មវិធីទូរស័ព្ទដៃ NoDrug បានចំនួន **៣.១៤៨នាក់** (កើនឡើង **២៤,២%** បើធៀបនឹងខែមិថុនាកន្លងទៅ) ធ្វើឱ្យចំនួនអ្នកទាញយកនិងប្រើប្រាស់សរុបកើនឡើងដល់ចំនួន **១០១.៦៨៨នាក់**។

## ២. ការពង្រឹងប្រសិទ្ធភាពការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល ស្ដារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត បានយកចិត្តទុកដាក់ពង្រឹងគុណភាពសេវាព្យាបាល ការស្ដារនីតិសម្បទា និងការធ្វើសមាហរណកម្ម នៅតាមមូលដ្ឋានសុខាភិបាលសាធារណៈ និងមជ្ឈមណ្ឌលព្យាបាលរបស់រដ្ឋ និងឯកជន ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖ ร

## ២.១.ការកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន

សម្របសម្រួលនិងអនុវត្តកម្មវិធីកាត់បន្ថយគ្រោះថ្នាក់បណ្តាលមកពីការប្រើប្រាស់គ្រឿងញៀន ទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- ក្រសួងសុខាភិបាល បានផ្តល់សេវាព្យាបាលឱសថជំនួសដោយមេតាដូន ដល់អ្នកញៀនគ្រឿងញៀន(ហេរ៉ូអ៊ីន) ចំនួន **៥០នាក់** ស្រី ៨នាក់ ដែលមានទីតាំងនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត ចំនួន ១៦នាក់ ស្រី ៤នាក់ និងមន្ទីរបង្អែកច្បារអំពៅចំនួន ៣៤នាក់ ស្រី ៤នាក់
- អង្គការដៃគូបានអនុវត្តកម្មវិធីផ្តល់សេវាម្ជុល-សឺរ៉ាំង ចំពោះអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់ ដើម្បីបង្ការទប់ស្កាត់ការឆ្លងមេរោគអេដស៍ និងជំងឺឆ្លងផ្សេងៗតាមឈាម ចំនួន **៨១២នាក់** ស្រី ១៤០នាក់(ថយចុះ ៣០នាក់ ស្មើនឹង **៣,៥៦%**) បើធៀបនឹងខែមិថុនា មានចំនួន ៨៤២នាក់
- រៀបចំលិខិតគាំទ្រដល់អង្គការកសាង ដែលបាននិងកំពុងអនុវត្តកម្មវិធីផ្តល់សេវាម្ជុល-សឺរ៉ាំង ចំពោះអ្នកប្រើប្រាស់គ្រឿងញៀនដោយចាក់។

## ២.២.ការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

សម្របសម្រួល និងពង្រឹងសមត្ថភាពការងារព្យាបាល ស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម ទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- ក្រសួងសុខាភិបាលបានផ្តល់សេវាព្យាបាលដល់អ្នកប្រើប្រាស់ អ្នកញៀនគ្រឿងញៀនដោយស្ម័គ្រចិត្ត និងផ្អែកលើសហគមន៍ ចំនួន **៥៩៣នាក់** ស្រី ៣២នាក់ រួមមាននៅមន្ទីរពេទ្យបង្អែកចំនួន ៥៦៥នាក់ ស្រី ២១នាក់ និងមណ្ឌលសុខភាពចំនួន ២៨នាក់ ស្រី ១១នាក់។ ដោយឡែកមណ្ឌលសុខភាពដែលមានទីតាំងក្នុងមជ្ឈមណ្ឌលជាតិព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន ចំនួន ៣៦៤នាក់ ស្រី ២៣នាក់ ក្នុងនោះមជ្ឈមណ្ឌលជាតិកែវផុសចំនួន ១៧៦នាក់ ស្រី ៨នាក់ និងមជ្ឈមណ្ឌលឱកាសខ្ញុំចំនួន ១៨៨នាក់ ស្រី ១៥នាក់
- ការព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅតាមមជ្ឈមណ្ឌលព្យាបាល និងស្តារនីតិសម្បទារបស់រដ្ឋ និងឯកជន រួមមាន អ្នកចូលថ្មីចំនួន **២.០៧៨នាក់** ស្រី ២០៥នាក់ (ខែមិថុនាមានចំនួន ២.១០៦នាក់ ស្រី១២៥នាក់) អ្នកធ្វើសមាហរណកម្មចំនួន **១.៩០៣នាក់** ស្រី ១៧០នាក់ (ខែមិថុនាមានចំនួន ១.៦២៩នាក់ ស្រី ១១០នាក់) និងអ្នកកំពុងស្នាក់នៅចំនួន **៩.៥៥៨នាក់** ស្រី ៥៨៦នាក់ (ខែមិថុនាមានចំនួន ៩.៣៨៣នាក់ ស្រី ៥៥១នាក់)
- ចូលរួមកិច្ចប្រជុំរបស់គណៈកម្មាធិការទទួលបន្ទុកការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅទីស្តីការក្រសួងសុខាភិបាល
- ចូលរួមកិច្ចប្រជុំលើកទី៣១ របស់ក្រុមការងារព្យាបាល និងស្តារនីតិសម្បទានៃយន្តការមន្ត្រីជាន់ខ្ពស់អាស៊ាន ស្តីពីបញ្ហាគ្រឿងញៀន តាមប្រព័ន្ធអនឡាញ។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

ដើម្បីពង្រឹងប្រសិទ្ធភាពការងារអនុវត្តច្បាប់ និងទប់ស្កាត់ការចរាចរគ្រឿងញៀនឆ្លងដែន បានសហការជាមួយស្ថាប័នអនុវត្តច្បាប់ទាំងក្នុងក្របខ័ណ្ឌជាតិ និងអន្តរជាតិ ក្នុងការបង្កើនកិច្ចសហប្រតិបត្តិការទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគីជាមួយអន្តរជាតិ តំបន់ អនុតំបន់ សម្រេចបានលទ្ធផលដូចខាងក្រោម៖

## ៣.១. ការពង្រឹងសមត្ថភាពការងារអនុវត្តច្បាប់

ក្នុងក្របខ័ណ្ឌនៃការពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ បានសហការសម្របសម្រួលក្នុងការរៀបចំ ចូលរួមកិច្ចប្រជុំ វគ្គបណ្តុះបណ្តាល និងកម្មវិធីនានា ដោយទទួលបាននូវលទ្ធផលដូចខាងក្រោម៖

- ចូលរួមកិច្ចប្រជុំបណ្តាញត្រួតពិនិត្យគ្រឿងញៀនអាស៊ានលើកទី២១(ADMN) និងសិក្ខាសាលាស្តីពីប្រព័ន្ធទិន្នន័យក្រោមក្របខ័ណ្ឌASEAN-NARCO តាមប្រព័ន្ធអនឡាញ
- ចូលរួមកិច្ចប្រជុំលើកទី៣៩ របស់មន្ត្រីជាន់ខ្ពស់អាស៊ាន ស្តីពីបញ្ហាគ្រឿងញៀន ក្រុមការងារផ្នែកអនុវត្តច្បាប់(39th ASOD WG on LE) តាមប្រព័ន្ធអនឡាញ
- ចូលរួមប្រចាំការនៅមជ្ឈមណ្ឌលសម្របសម្រួលសុវត្ថិភាពទន្លេមេគង្គ(SMCC) នៅប្រទេសវៀតណាម
- ចូលរួមកិច្ចប្រជុំក្រុមការងារទទួលបន្ទុករៀបចំយុទ្ធសាស្ត្រជាតិ និងត្រៀមទទួលការវាយតម្លៃអញ្ញមញ្ញឆ្នាំ២០២៨-២០២៩ ស្តីពីការប្រឆាំងការសម្អាតប្រាក់ ហិរញ្ញប្បទានភេរវកម្ម និងហិរញ្ញប្បទានដល់ការរីកសាយភាយអាវុធមហាប្រល័យ ដែលរៀបចំដោយអង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុកម្ពុជា នៅរាជធានីភ្នំពេញ
- ចូលរួមវគ្គបណ្តុះបណ្តាលលើកកម្ពស់សមត្ថភាពការស៊ើបអង្កេតបទល្មើស និងត្រួតពិនិត្យគ្រឿងញៀនសម្រាប់មន្ត្រីអនុវត្តច្បាប់ នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម
- ទទួលការរាយការណ៍ពីបញ្ហាគ្រឿងញៀន តាមរយៈកម្មវិធីទូរស័ព្ទដៃ NoDrug ប្រចាំខែកក្កដា មានចំនួន **១.៣២២ករណី** (ថយចុះ ២០១ករណី ស្មើនឹង **១៣,២%**) បើធៀបនឹងខែមិថុនា មានចំនួន ១.៥២៣ករណី ក្នុងនោះដោះស្រាយរួច ១.១៨៧ករណី កំពុងដោះស្រាយ ៤២ករណី ព័ត៌មានមិនត្រឹមត្រូវ ៣៦ករណី សាកល្បង ៣ករណី ករណីដដែល ៤៨ករណី និងផ្សេងៗ ៦ករណី
- បញ្ចូលទិន្នន័យព័ត៌មានពាក់ព័ន្ធករណីបង្ក្រាបបទល្មើសគ្រឿងញៀនធំៗចាប់ពី ១គីឡូក្រាមឡើងទៅក្នុងប្រព័ន្ធទិន្នន័យរបស់គម្រោងសុវត្ថិភាពទន្លេមេគង្គ(SMCC)បានចំនួន ៧ករណី ជនសង្ស័យចំនួន ១០នាក់ ស្រី ២នាក់ គ្រឿងញៀនចំនួន ២៥គីឡូក្រាម។

## ៣.២. លទ្ធផលបង្ក្រាបបទល្មើសគ្រឿងញៀន

តាមរយៈកិច្ចប្រតិបត្តិការរបស់កម្លាំងអនុវត្តច្បាប់ក្នុងការបង្ក្រាបបទល្មើសគ្រឿងញៀន ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

- បង្ក្រាបបទល្មើសគ្រឿងញៀនសរុបចំនួន **១.០២៦ករណី** (ថយចុះ ៧៣ករណី ស្មើនឹង **៦,៦៤%**) បើធៀបនឹងខែមិថុនា មានចំនួន ១.០៩៩ករណី។ ឃាត់ខ្លួនជនសង្ស័យសរុបចំនួន **២.៧០២នាក់** ស្រី ១៩៧នាក់(ថយចុះ ៥០៩នាក់ ស្មើនឹង **១៥,៨%**) បើធៀបនឹងខែមិថុនា មានចំនួន ៣.២១១នាក់ ក្នុងនោះជនជាតិខ្មែរ ២.៥៩៤នាក់(ស្រី ១៧៨នាក់) និងជនជាតិបរទេស ១០៨នាក់(ស្រី ១៩នាក់) រួមមាន ចិន ៤៨នាក់(ស្រី ៥នាក់) ក្នុងនោះចិនតៃវ៉ាន់ ៩នាក់(ស្រី ៣នាក់) វៀតណាម ៤០នាក់(ស្រី ១២នាក់) ថៃ ៨នាក់(ស្រី ១នាក់) ឥណ្ឌា ៤នាក់ ឥណ្ឌូនេស៊ី ៣នាក់(ស្រី ១នាក់) អង់គ្លេស ៣នាក់ និងបង់ក្លាដេស ២នាក់
- ចាប់យកគ្រឿងញៀន ចំនួន **៦៤គ.ក្រ ៧២២.៤១ក្រាម**(កើនឡើង ១គ.ក្រ ២៦៣.៦ក្រាម ស្មើនឹង **១,៩៩%**) បើធៀបនឹងខែមិថុនា មានចំនួន ៦៣គ.ក្រ ៤៥៨.៨១ក្រាម
- ចាប់យកសារធាតុគីមីផ្សំនិងសារធាតុគីមីពាក់ព័ន្ធ ចំនួន **៤២.៣៧គីឡូក្រាម**
- ចាប់យកកញ្ឆាស្ងួត ចំនួន **៣០គីឡូក្រាម ៦២៧ក្រាម** និងកញ្ឆាស្រស់ **១៦ដើម**។

– ចាប់យកសម្ភារក្នុងប្រតិបត្តិការបង្ក្រាបបទល្មើសគ្រឿងញៀន ដែលបានបញ្ជូនទៅសាលាដំបូងរាជធានី ខេត្ត រួមមាន រថយន្ត ៦គ្រឿង ម៉ូតូ ២១៨គ្រឿង ទូរស័ព្ទ ១.១៥៣គ្រឿង ជញ្ជីង ១០០គ្រឿង អាវុធខ្លី ៥ដើម និងរូបិយវត្ថុជាតិ រូបិយប័ណ្ណអន្តរជាតិ(៧.៩០៦.៩០០រៀល និង១១.៣៣៣ដុល្លារ)

– អនុវត្តដីកា បានចំនួន ៧៤ដីកា ចាប់ខ្លួនជនសង្ស័យចំនួន ៦៤នាក់

– **ក្នុងចំនួនករណីគ្រឿងញៀនខាងលើ៖**

- ករណីបង្ក្រាបដោយសមត្ថកិច្ចនគរបាលចំនួន **៨៩៤ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន ២.៤០០នាក់ (ស្រី ១៧១នាក់)
- ករណីបង្ក្រាបដោយសមត្ថកិច្ចកងរាជអាវុធហត្ថចំនួន **១៣២ករណី** ឃាត់ខ្លួនជនសង្ស័យចំនួន ៣០២នាក់ (ស្រី ២៦នាក់)

– **ការកត់សម្គាល់លើបទល្មើសគ្រឿងញៀន៖**

- ករណីធំៗ ចាប់ពី **១គីឡូក្រាមឡើង** មាន **៨ករណី** (ចោទពីបទសម្អាតប្រាក់គ្មាន) ឃាត់ខ្លួនជនសង្ស័យបាន **៣៤នាក់(ស្រី ៣នាក់)** ក្នុងនោះខ្មែរ ២៥នាក់(ស្រី ៣នាក់) ចិន ៤នាក់ ឥណ្ឌា ៣នាក់ និងវៀតណាម ២នាក់ ចាប់យកគ្រឿងញៀន **៥៣គីឡូក្រាម ១៣១.០៧ក្រាម** និងកញ្ឆាក្រៀម **១១គីឡូក្រាម ៨៤៣.៤៧ក្រាម**
- ករណីមធ្យម ចាប់ពី ១០០ក្រាមឡើង មាន ១២៦ករណី ឃាត់ខ្លួនជនសង្ស័យ ៣១៤នាក់
- ករណីតូចតាច ចាប់ពី ៩៩ក្រាមចុះក្រោម មាន ៨៩២ករណី ឃាត់ខ្លួនជនសង្ស័យ ២.៣៥៤នាក់។

### ៣.៣. ការអនុវត្តវិធានការរដ្ឋបាល

ការចាត់តាំងអនុវត្តវិធានការរដ្ឋបាលបានចំនួន **៧៤៤លើក** ក្នុងនោះ ចុះអប់រំម្ចាស់ទីតាំងអាជីវកម្មបាន ៣៨០លើក រួមមាន **៣គោលដៅ (**ផ្ទះសំណាក់ ផ្ទះជួល និងKTV) និងអញ្ជើញម្ចាស់ទីតាំងអាជីវកម្មមកប្រជុំបាន **៣៦៤លើក** អ្នកចូលរួមចំនួន **១១.៩៦៥នាក់**(ស្រី ៥.៨៤៥នាក់) ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត ចុះធ្វើតេស្តហ័សរកសារធាតុញៀនលើក្រុមគោលដៅបានចំនួន **៩៩លើក** លើមុខសញ្ញាចំនួន **១.២៣៤នាក់**(ស្រី ១៨៤នាក់) រកឃើញវិជ្ជមានសារធាតុញៀន **១៥០នាក់** ត្រូវបានសមត្ថកិច្ចបញ្ជូនតាមនីតិវិធីច្បាប់ទៅទទួលយកសេវាបន្សាបនិងព្យាបាល។

### ៣.៤.ការងារមន្ទីរពិសោធន៍គ្រឿងញៀន

– បានធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀន ចំនួន **៧៥៣សំណាក** ស្មើនឹង **៥០៣ករណី** ក្នុងនោះ សំណាកវិជ្ជមានសារជាតុញៀនចំនួន **៧៣០សំណាក** ស្មើនឹង **៩៦,៩៥%** និងសំណាកអវិជ្ជមានសារជាតុញៀនចំនួន **២៣សំណាក** ស្មើនឹង **៣,០៥%**

– ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី៣ របស់ក្រុមការងារកោសល្យវិច័យ នៃយន្តការប្រទេសហត្ថលេខីអនុស្សរណៈនៃការយោគយល់គ្នាឆ្នាំ១៩៩៣ (Mekong MOU) នៅប្រទេសចិន

– បានផ្តល់ឧបករណ៍តេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជំហានដំបូងប្រភេទម៉ាគីតេស្ត (Marquis test) និងប្រភេទកេតាមីន( Ketamine test ) បានចំនួន **៧.១០០តេស្ត** និងកញ្ចប់រក្សាវត្ថុតាងចំនួន **២០០កញ្ចប់**

– បានផ្តល់តេស្តហ័សរកសារធាតុញៀនតាមទឹកមូត្រប្រភេទមេតំហ្វេតាមីន ចំនួន **១៦.០០០តេស្ត** ជូនដល់ក្រសួងការពារជាតិ រដ្ឋបាលខេត្តកំពង់ស្ពឺ ព្រះសីហនុ រតនគិរី មណ្ឌលគិរី ព្រះវិហារ ត្បូងឃ្មុំ កំពត រដ្ឋបាលខេត្តស្វាយរៀង ស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ និងកងរាជអាវុធហត្ថខេត្តកំពង់ស្ពឺ។

## ៤. ការត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ

បានអនុវត្តសកម្មភាពការងារគ្រប់គ្រងត្រួតពិនិត្យសារធាតុញៀននិងសារធាតុគីមីផ្សំ ដើម្បីបង្ការទប់ស្កាត់ប្រកបដោយប្រសិទ្ធភាពនូវការលួចបង្វែរពីជំនួញស្របច្បាប់ យកទៅកែច្នៃគ្រឿងញៀនខុសច្បាប់ ទទួលបានលទ្ធផលដូចខាងក្រោម៖

– ជំរុញក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យានិងនវានុវត្តន៍ ក្រសួងសុខាភិបាល និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បន្តសហការសម្របសម្រួលជាមួយក្រុមហ៊ុន រោងចក្រ សហគ្រាស អំពីការគ្រប់គ្រងការប្រើប្រាស់សារធាតុគីមីផ្សំស្ថិតក្រោមច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេស និងគោលការណ៍ណែនាំ

– ចូលរួមកិច្ចប្រជុំប្រចាំឆ្នាំលើកទី៣ របស់ក្រុមការងារត្រួតពិនិត្យសារធាតុគីមីផ្សំ នៃយន្តការប្រទេសហត្ថលេខីអនុស្សរណៈនៃការយោគយល់គ្នាឆ្នាំ១៩៩៣ (Mekong MOU) នៅប្រទេសចិន

– សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័នជំនាញ បន្តជំរុញចុះត្រួតពិនិត្យការប្រើប្រាស់សារធាតុគីមីផ្សំគ្រឿងញៀននៅតាមបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស ឱ្យបានជាប្រចាំ

– ក្រសួង ស្ថាប័នជំនាញមានសមត្ថកិច្ចពាក់ព័ន្ធ បានផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាតដល់ក្រុមហ៊ុន រោងចក្រ សហគ្រាស ក្នុងការនាំចូលនូវវត្ថុធាតុដើមផលិតឱសថ និងសារធាតុគីមីផ្សំ ដែលបានកំណត់ក្នុងតារាងឧបសម្ព័ន្ធនៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀនចំនួន **១២៦.៧៤៩តោន ៨៨២គ.ក្រ** (កើនឡើង ១២៦.២៨៩តោន ១៨២គ.ក្រ ស្មើនឹង **២៧.៤១២,៤%**) បើធៀបនឹងខែមិថុនា មានចំនួន ៤៦០តោន ៧០០គ.ក្រ។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

ដើម្បីពង្រឹង និងពង្រីកប្រសិទ្ធភាពកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនទ្វេភាគីជាមួយបណ្តាប្រទេសជាប់ព្រំដែន សម្រេចបានលទ្ធផលដូចខាងក្រោម៖

– បាននិងកំពុងបន្តពង្រឹងប្រសិទ្ធភាពការងារការិយាល័យទំនាក់ទំនងព្រំដែន(BLO) ជាប់ជាប្រចាំ

– បាននិងកំពុងបន្តពង្រឹងយន្តការភូមិ ឃុំ សង្កាត់ សគ្មានគ្រឿងញៀន ជាមួយបណ្តាប្រទេសជាប់ព្រំដែន។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់និងដៃគូអភិវឌ្ឍន៍នានា

សម្របសម្រួលកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី តំបន់ អនុតំបន់ អន្តរជាតិ និង UNODC ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

**– ឯកឧត្តម ព្រុំ សុខា ទេសរដ្ឋមន្ត្រី អនុប្រធានប្រចាំការនៃ អ.ជ.ប.គ.ញ.** បានអនុញ្ញាតឱ្យឯកឧត្តម **Steven Pang** ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋសិង្ហបុរីប្រចាំកម្ពុជាទើបតែងតាំងថ្មី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅទីស្តីការក្រសួងមហាផ្ទៃ

– ឯកឧត្តម **កេត សោផាន់** រដ្ឋលេខាធិការទីស្តីគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មការទទួលបន្ទុកកិច្ចសហប្រតិបត្តិការអន្តរជាតិ បានចូលជួបសម្តែងការគួរសមជាមួយឯកឧត្តម **Mesut Ozcan** ឯកអគ្គរដ្ឋទូតតួកគីយ៉េ ឯកឧត្តម **Vanlalvwna Bawitlung** ឯកអគ្គរដ្ឋទូតឥណ្ឌា និងឯកឧត្តម **Shaharuddin Onn** ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំប្រទេសកម្ពុជា ពិភាក្សាការងារពាក់ព័ន្ធកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.៩

– ឯកឧត្តម នាយឧត្តមសេនីយ៍ អគ្គលេខាធិការ នៃអ.ជ.ប.គ.ញ. អនុញ្ញាតឱ្យលោក Abraham Avarn លេខាទី២នៃសាធារណរដ្ឋឥណ្ឌាប្រចាំកម្ពុជា ចូលជួបសម្ដែងការគួរសម និងពិភាក្សាការងារពាក់ព័ន្ធកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

– ចូលរួមកិច្ចប្រជុំផ្ដល់ធាតុចូល និងចែករំលែកបទពិសោធន៍ក្នុងកិច្ចប្រជុំលើកទី៣០ នៃក្រុមការងារស្រាវជ្រាវ ក្រោមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានទទួលបន្ទុកបញ្ហាគ្រឿងញៀន(ASOD) ដែលរៀបចំដោយការិយាល័យកណ្ដាលគ្រឿងញៀនសិង្ហបុរី(CNB) តាមប្រព័ន្ធអនឡាញ

– ចូលរួមកិច្ចប្រជុំលើកទី២០ នៃក្រុមការងារមន្ត្រីជាន់ខ្ពស់អាស៊ានទទួលបន្ទុកគ្រឿងញៀន ស្ដីពីការអភិវឌ្ឍជំណាំជំនួស ដែលរៀបចំដោយអង្គភាពប្រយុទ្ធប្រឆាំងគ្រឿងញៀនម៉ាឡេស៊ី(NADA) តាមប្រព័ន្ធអនឡាញ

– ផ្ដល់ធាតុចូលសម្រាប់រៀបចំកិច្ចប្រជុំពិគ្រោះយោបល់ទ្វេភាគីលើកទី៣ រវាងកម្ពុជា-រុស្ស៊ី និងរបាយការណ៍វឌ្ឍនភាពនៃកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-អូស្ត្រាលី-នូវែលសេឡង់-មីយ៉ាន់ម៉ា និងសេចក្ដីព្រាងកំណត់ហេតុកិច្ចប្រជុំJCBC កម្ពុជា-ម៉ាឡេស៊ី លើកទី៣ ជូនក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

បានពង្រឹងយន្តការ និងធ្វើជាសេនាធិការក្នុងការចាត់តាំងដឹកនាំអនុវត្តការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាលក្ខណៈពហុវិស័យនៅថ្នាក់ជាតិ និងនៅថ្នាក់ក្រោមជាតិ ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

– អនុវត្តបទបញ្ជាលេខ០១ បប របស់រាជរដ្ឋាភិបាល ស្ដីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ ដោយបានធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រ ចំពោះមន្ត្រីរាជការស៊ីវិល នគរបាលជាតិ យោធិន និងមន្ត្រីជាប់កិច្ចសន្យា មកដល់បច្ចុប្បន្ននេះ**ចំនួន ១៤៥.១០២នាក់** ក្នុងនោះរកឃើញវិជ្ជមានសារធាតុញៀនចំនួន ១១២នាក់ បណ្ដេញចេញពីក្របខ័ណ្ឌចំនួន ១០៩នាក់ និងកំពុងតាមដាន ៣នាក់។

– ជំរុញការអនុវត្តបទបញ្ជាលេខ០២ បប របស់រាជរដ្ឋាភិបាលកម្ពុជា ស្ដីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្ដុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា

– ជំរុញក្រសួង ស្ថាប័ន និងរដ្ឋបាលរាជធានី ខេត្ត បន្តអនុវត្តសេចក្ដីណែនាំ ស្ដីពីដំណើរការធ្វើតេស្តរហ័សរកសារធាតុញៀនក្នុងទឹកមូត្រ

– ជំរុញការអនុវត្តផែនការយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១

– ប្រជុំត្រួតពិនិត្យលើការងាររបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ខែមិថុនា និងលើកទិសដៅការងារខែកក្កដាឆ្នាំ២០២៦ នៅអគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ.

– ធ្វើបទឧទ្ទេសនាម ស្ដីពីគ្រឿងញៀនក្នុងកម្មវិធីគ្រប់គ្រងកម្រិត១ឆ្នាំ២០២៦ របស់សាលាជាតិរដ្ឋបាលមូលដ្ឋាន ក្រសួងមហាផ្ទៃ តាមប្រព័ន្ធអនឡាញ

– កិច្ចប្រជុំសម្អាតទិន្នន័យដែលទទួលបានពីដំណើរការអង្កេត ស្ដីពីការយល់ឃើញរបស់ប្រជាពលរដ្ឋលើបញ្ហាគ្រឿងញៀន នៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ

– សិក្ខាសាលា ស្ដីពីការលើកកម្ពស់ការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន និងពង្រឹងការចូលរួមទប់ស្កាត់ការចរាចរគ្រឿងញៀនឆ្លងកាត់អាកាសយានដ្ឋាន ដែលរៀបចំដោយរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល នៅរាជធានីភ្នំពេញ។

– កិច្ចប្រជុំពិភាក្សាកម្រិតបច្ចេកទេស លើគម្រោងផែនការចំណូល ចំណាយថវិកាឆ្នាំ២០២៧ របស់អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយតំណាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅទីស្តីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

– ជាវាគ្មិនក្នុងកម្មវិធីផ្សព្វផ្សាយច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ដែលរៀបចំដោយក្រសួងអធិការកិច្ច នៅខេត្តត្បូងឃ្មុំ

– សហការសម្របសម្រួលជាមួយក្រសួង ស្ថាប័ន គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត ជំរុញឱ្យមានប្រសិទ្ធភាពការងារផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃការប្រើប្រាស់គ្រឿងញៀន និងការបង្ក្រាបបទល្មើសគ្រឿងញៀន នៅតាមបណ្តាភូមិសាស្ត្រស្មុគស្មាញ។

**ក្រៅពីលទ្ធផលសកម្មភាពការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខាងលើ អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. បានចាត់បញ្ជូនថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋាន និងមន្ត្រី** ចូលរួមដូចខាងក្រោម៖

– ក្នុងពិធីសម្ពោធដាក់ឱ្យប្រើប្រាស់ជាផ្លូវការ កំណាត់ផ្លូវជាតិលេខ៧(ស្គន់-ក្រុងកំពង់ចាម) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅស្រុកព្រៃឈរ ខេត្តកំពង់ចាម

– ក្នុងពិធីបើកពិព័រណ៍«ពន្លកបៃតង» ឆ្នាំ២០២៦ ក្រោមអធិបតីភាព**ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន ឧបនាយករដ្ឋមន្ត្រី** តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយក-រដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅទីស្តីការក្រសួងបរិស្ថាន

– ក្នុងកម្មវិធី«ខួប២០ឆ្នាំ» នៃអង្គការTransform Cambodia ក្រោមអធិបតីភាព**ឯកឧត្តមសន្តិបណ្ឌិត នេត សាវឿន នាយករដ្ឋមន្ត្រីស្តីទី** តំណាងដ៏ខ្ពង់ខ្ពស់**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសាលមហោស្រពកោះពេជ្រ**

– កិច្ចប្រជុំផ្សព្វផ្សាយប្រកាសដាក់ឱ្យអនុវត្តអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធិពេញលេញ និងពិធីប្រកាសសមាសភាពថ្នាក់ដឹកនាំលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រឆាំងទារុណកម្ម(គ.ជ.ប.ទ.) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ

– ពិធីប្រគល់វិញ្ញាបនបត្រសិក្សា និងទទួលសៀវភៅ «អភិសមាចារនិងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់មន្ត្រីនគរបាលជាតិ» ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅបណ្ឌិត្យសភានគរបាលកម្ពុជា ខេត្តកណ្តាល

– កិច្ចប្រជុំប្រចាំខែកក្កដា ស្តីពីការសម្របសម្រួលការងារអន្តរអង្គភាពចំណុះក្រសួងមហាផ្ទៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** នៅទីស្តីការក្រសួងមហាផ្ទៃ

– វេទិកាថ្នាក់តំបន់លើកទី២ ស្តីពីផែនការយុទ្ធសាស្ត្រសហគមន៍សង្គម វប្បធម៌អាស៊ាន ក្រោមប្រធានបទ«ការដាក់បញ្ចូលផែនការយុទ្ធសាស្ត្រទៅក្នុងការអភិវឌ្ឍន៍ផែនការ ថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់» តាមប្រព័ន្ធអនឡាញ

– ពិធីប្រកាសចូលកាន់មុខតំណែងអភិបាលរងនៃគណៈអភិបាលខេត្តសៀមរាប

– កិច្ចប្រជុំផ្សព្វផ្សាយដំណើរការរៀបចំជំរឿនមន្ត្រីនគរបាលជាតិកម្ពុជា និងកិច្ចប្រជុំក្រុមលេខាធិការដ្ឋាននៃក្រុមការងារទទួលបន្ទុកបច្ចុប្បន្នភាពរចនាសម្ព័ន្ធ និងជំរឿនមន្ត្រីជាក់ស្តែងនៅតាមរចនាសម្ព័ន្ធរបស់ក្រសួងមហាផ្ទៃ នៅទីស្តីការក្រសួងមហាផ្ទៃ៦

– សិក្ខាសាលាពិគ្រោះយោបល់លើសេចក្ដីព្រាងផែនការយុទ្ធសាស្ត្របញ្ជ្រាបយេនឌ័រ ឆ្នាំ២០២៦-២០៣០ របស់ក្រុមការងារយេនឌ័រក្រសួងមហាផ្ទៃ នៅទីស្ដីការក្រសួងមហាផ្ទៃ

– រៀបចំ និងចូលរួមកិច្ចប្រជុំបច្ចេកទេស ស្ដីពីរបាយការណ៍ពាក់កណ្ដាលអាណត្តិ នៃយន្តការពិនិត្យជាសកលតាមកាលកំណត់(UPR) នៅគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា

– ប្រកាសតែងតាំងផ្លាស់ប្ដូរមុខតំណែងនាយទាហានជាន់ខ្ពស់ នៃកងពលតូចថ្មើរជើង៣១ នៅខេត្តកំពត

– កិច្ចប្រជុំអន្តរក្រសួងកម្រិតថ្នាក់ដឹកនាំ ដើម្បីពិនិត្យនិងពិភាក្សាលើសេចក្ដីព្រាងរបាយការណ៍ស្ដីពីសកម្មភាពការងាររបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាប្រចាំឧសភាឆ្នាំ២០២៦ នៅទីស្ដីការគណៈរដ្ឋមន្ត្រី

– កិច្ចប្រជុំគណៈកម្មការអន្តរក្រសួងសម្រាប់អនុវត្តគោលដៅប្រកបដោយចីរភាពឆ្នាំ២០១៦-២០៣០ នៅទីស្ដីការក្រសួងផែនការ

– សិក្ខាសាលាផ្សព្វផ្សាយ ស្ដីពីបង្កើនការយល់ដឹងរួមគ្នាពីហានិភ័យនៃមេរោគអេដស៍ និងជំងឺអេដស៍ ការមាក់ងាយ និងការរើសអើង នៅបណ្ឌិត្យសភានគរបាលកម្ពុជាខេត្តកណ្ដាល

– កិច្ចប្រជុំក្រុមការងារកម្រិតបច្ចេកទេស នៃក្រុមការងារតាមដានជំរុញការអភិវឌ្ឍ និងដាក់ឱ្យដំណើរការប្រព័ន្ធ «MohaPhtey App» នៅទីស្ដីការក្រសួងមហាផ្ទៃ។

## III. ទិសដៅការងារប្រយុទ្ធប្រឆាំងគ្រឿងញៀនខែសីហា ឆ្នាំ២០២៦

ដើម្បីពង្រឹងប្រសិទ្ធភាពការងារប្រយុទ្ធប្រឆាំងគ្រឿងញៀន អគ្គលេខាធិការដ្ឋាននៃ អ.ជ.ប.គ.ញ. បានដាក់ចេញនូវទិសដៅការងារខែសីហា ឆ្នាំ២០២៦ ដូចខាងក្រោម៖

### ១. ការផ្សព្វផ្សាយអប់រំ បង្ការ ទប់ស្កាត់ និងបដិសេធគ្រឿងញៀន

**១.១.** បន្តសហការនិងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ពង្រឹងការងារផ្សព្វផ្សាយអប់រំ តាមរយៈវិទ្យុ ទូរទស្សន៍ ទូរស័ព្ទដៃ សិល្បៈភាពយន្ត លើស្លាកសញ្ញាផលិតផលក្នុងស្រុក និងតាមរយៈប្រព័ន្ធទំនាក់ទំនងសង្គមផ្សេងទៀត។

**១.២.** បន្តសម្របសម្រួលនិងជំរុញក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ផលិតមាតិកាពាក់ព័ន្ធការផ្សព្វផ្សាយអប់រំអំពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន។

**១.៣.** បន្តសហការនិងជំរុញរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដើម្បីជំរុញការទាញយក និងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug។

**១.៤.** បន្តពង្រឹងការបញ្ជ្រាបខ្លឹមសារអប់រំអំពីផលប៉ះពាល់ និងគ្រោះថ្នាក់នៃគ្រឿងញៀនតាមរយៈសកម្មភាពផ្សេងៗរបស់ដៃគូ។

**១.៥.** បន្តសហការនិងសម្របសម្រួលដើម្បីត្រៀមរៀបចំចុះអនុស្សរណៈនៃការយោគយល់រវាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន សហព័ន្ធកីឡាបាល់ទាត់ និងសហភាពសហព័ន្ធយុវជនកម្ពុជា។

**១.៦.** បន្តចលនា កៀរគរឱ្យមានការចូលរួមផុលផុសនិងគាំទ្រពីគ្រប់មជ្ឈដ្ឋានសង្គមលើការងារផ្សព្វផ្សាយអប់រំ ស្ដីពីបញ្ហាគ្រឿងញៀន។

**១.៧.** បន្តចុះត្រួតពិនិត្យនិងការអនុវត្តកម្មវិធី«គ្រួសាររឹងមាំ Strong Family» ដំណាក់កាលទី៣ ដល់ក្រុមគ្រួសារនៃសហគមន៍ក្រុមប្រឹក្សាបណ្ដាញព្រះវិហារគ្រីស្ទបរិស័ទកម្ពុជា នៅខេត្តព្រះសីហនុ។

**១.៨.** បន្តកៀរគរដៃគូMOU ផលិតបទចម្រៀងអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន។

**១.៩.** បន្តសហការជាមួយក្រសួងទេសចរណ៍ ចុះផ្សព្វផ្សាយអប់រំពីគ្រោះថ្នាក់នៃគ្រឿងញៀន និងជំរុញការទាញយកនិងប្រើប្រាស់កម្មវិធីទូរស័ព្ទដៃ NoDrug ដល់ប្រតិបត្តិករនិងបុគ្គលិកបម្រើការនៅតាមមូលដ្ឋាន អាជីវកម្មសេវាកម្មទេសចរណ៍ ខេត្តពោធិ៍សាត់។

**១.១០.** បន្តសហការជាមួយតំណាងអង្គការUNODC ដើម្បីអនុវត្តខ្លឹមសារនៃកិច្ចប្រជុំថ្នាក់ជាតិ ស្តីពីការបង្ការ ការអប់រំ អំពីការប្រើប្រាស់គ្រឿងញៀននៅកម្ពុជា។

**១.១១.** បន្តសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា ដំណើរការប្រកួតស្នាដៃផលិតវីដេអូអប់រំខ្លីក្រោមប្រធានបទ«ពលរដ្ឋរួមគ្នាប្រយុទ្ធប្រឆាំងគ្រឿងញៀន ដើម្បីសន្តិភាព សន្តិសុខ និងការអភិវឌ្ឍ» ក្នុងចំណោមគរុសិស្សនៃសាលាគរុកោសល្យ និងវិក្រឹតការទូទាំងប្រទេស។

**១.១២.** ត្រៀមចូលរួមផ្សព្វផ្សាយ អប់រំ ស្តីពីផលប៉ះពាល់និងគ្រោះថ្នាក់នៃគ្រឿងញៀន ក្នុងកម្មវិធីចុះពង្រឹងការទប់ស្កាត់បទល្មើសគ្រឿងញៀននៅមណ្ឌលអប់រំកែប្រែទី៤ នៅខេត្តពោធិ៍សាត់។

## ២. ការពង្រឹងប្រសិទ្ធភាពការងារព្យាបាល ស្តារនីតិសម្បទា និងសមាហរណកម្ម

**២.១.** បន្តសហការជាមួយក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្នុងការទទួលទិន្នន័យ និងធ្វើបច្ចុប្បន្នភាពអ្នកប្រើប្រាស់ និងអ្នកញៀនគ្រឿងញៀន។

**២.២.** បន្តរៀបចំបណ្តុះបណ្តាលការអនុវត្តផ្ទាល់ និងត្រួតពិនិត្យការប្រើប្រាស់សាកល្បងថ្នាលឌីជីថលប្រមូលទិន្នន័យអ្នកញៀនគ្រឿងញៀន នៅតាមមជ្ឈមណ្ឌលព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនរដ្ឋ និងឯកជន។

**២.៣.** បន្តសហការជាមួយក្រុមការងារ App NoDrug និងនាយកដ្ឋានអប់រំ ផ្សព្វផ្សាយ និងទំនាក់ទំនងសាធារណៈ ក្នុងការឆ្លើយតបមហាជនពាក់ព័ន្ធនឹងការបញ្ចេញមតិលើបណ្តាសង្គមពាក់ព័ន្ធនឹងការងារព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន។

**២.៤.** បន្តសម្របសម្រួលជាមួយតំណាងក្រសួងនគរបាលនៃសាធារណៈរដ្ឋសង្គមនិយមវៀតណាមពន្លឿននីតិវិធីក្នុងការស្នើសុំជំនួយសម្រាប់សាងសង់មជ្ឈមណ្ឌលជាតិព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅខេត្តស្វាយរៀង។

**២.៥.** ត្រៀមចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការងារព្យាបាលនិងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន នៅប្រទេសវៀតណាម។

## ៣. ការពង្រឹងប្រសិទ្ធភាពស្ថាប័នអនុវត្តច្បាប់

**៣.១.** បន្តពង្រឹងសមត្ថភាពមន្ត្រីអនុវត្តច្បាប់ ក្នុងការទប់ស្កាត់ជាអាទិភាពនូវការចរាចរគ្រឿងញៀនឆ្លងកាត់ព្រំដែន តាមផ្លូវគោក ទឹក អាកាស និងបញ្ញើប្រៃសណីយ៍។

**៣.២.** ត្រៀត្រៀមចុះពង្រឹង និងជំរុញការអនុវត្តតួនាទីភារកិច្ចរបស់ការិយាល័យទំនាក់ទំនងព្រំដែន(BLO) ទើបបង្កើតថ្មី។

**៣.៣.** ត្រៀមចូលរួមសិក្ខាសាលាថ្នាក់តំបន់ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការស៊ើបអង្កេតបទល្មើសគ្រឿងញៀនឆ្លងដែន នៅប្រទេសមីយ៉ាន់ម៉ា។

**៣.៤. ការងារមន្ទីរពិសោធន៍គ្រឿងញៀន៖**

– បន្តពិនិត្យ និងធ្វើកោសល្យវិច័យលើសំណាកវត្ថុតាងដែលសង្ស័យជាគ្រឿងញៀន ដើម្បីដោះស្រាយការកកស្ទះសំណុំរឿងរបស់សាលាដំបូងរាជធានី ខេត្ត៩

– បន្តផលិតឧបករណ៍តេស្តពណ៌សម្រាប់កំណត់អត្តសញ្ញាណគ្រឿងញៀនជំហានដំបូង ប្រភេទម៉ាគ្គីតេស្ត ( Marquis test) និងកេតាមីនតេស្ត ( Ketamine test ) ដើម្បីមានលទ្ធភាពផ្គត់ផ្គង់ឧបករណ៍ទាំងនេះ ដល់ស្ថាប័នអនុវត្តច្បាប់ សម្រាប់ប្រើប្រាស់ឱ្យបានគ្រប់គ្រាន់

– ផ្គត់ផ្គង់ឧបករណ៍ធ្វើតេស្តរហ័សកំណត់អត្តសញ្ញាណសារធាតុញៀនប្រភេទថ្មី(NIS) ជំហានដំបូងដល់មន្ត្រីអនុវត្តច្បាប់

– ត្រៀមចូលរួមធ្វើតេស្តរកសារធាតុញៀនក្នុងទឹកមូត្រជូនដល់មន្ត្រីរាជការតាមក្រសួង ស្ថាប័ន អង្គភាពមួយចំនួន។

## ៤. ការត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ

**៤.១.** បន្តចុះជួបប្រជុំផ្សព្វផ្សាយ និងពង្រឹងយន្តការគ្រប់គ្រងត្រួតពិនិត្យសារធាតុញៀន និងសារធាតុគីមីផ្សំ ជាមួយគណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត និងអង្គភាពគយនិងរដ្ឋាករតាមច្រកទ្វារព្រំដែន។

**៤.២.** បន្តសហការជាមួយក្រសួង ស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធ ចុះត្រួតពិនិត្យការប្រើប្រាស់សារធាតុគីមីផ្សំ នៅតាមបណ្តាក្រុមហ៊ុន រោងចក្រ សហគ្រាស ដើម្បីបង្ការទប់ស្កាត់ការលួចបង្វែរពីជំនួញស្របច្បាប់យកទៅផលិតគ្រឿងញៀនខុសច្បាប់។

## ៥. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសជាប់ព្រំដែន

**៥.១.** បន្តពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិ ទ្វេភាគី ត្រីភាគី ពហុភាគី ជាមួយប្រទេសជាប់ព្រំដែន តាមរយៈការអនុវត្តតាមកំណត់ហេតុកិច្ចប្រជុំដែលបានឯកភាព ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៥.២.** បន្តសម្របសម្រួល និងសហការជាមួយប្រទេសជាប់ព្រំដែន ដើម្បីពង្រឹងយន្តការការិយាល័យទំនាក់ទំនងព្រំដែន(BLO)។

**៥.៣.** ត្រៀមរៀបចំកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទ្វេភាគី ត្រីភាគី កម្ពុជា-វៀតណាម-ឡាវ លើកទី១៩ ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ដែលប្រទេសកម្ពុជាធ្វើជាម្ចាស់ផ្ទះ។

## ៦. កិច្ចសហប្រតិបត្តិការអន្តរជាតិជាមួយប្រទេសក្នុងតំបន់ និងដៃគូអភិវឌ្ឍន៍នានា

**៦.១.** បន្តជំរុញកិច្ចសហប្រតិបត្តិការទ្វេភាគី ពហុភាគីជាមួយបណ្តាប្រទេសក្នុងតំបន់ និងដៃគូដើម្បីអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការប្រយុទ្ធប្រឆាំងគ្រឿងញៀន។

**៦.២.** បន្តចូលរួមសហការសម្របសម្រួលអនុវត្តក្នុងភាពជាដៃគូ នៃកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀន ទាំងក្នុងក្របខ័ណ្ឌទ្វេភាគី ពហុភាគី ជាពិសេសបណ្តាប្រទេសក្នុងអនុតំបន់ តំបន់ និងអន្តរជាតិ។

**៦.៣.** បន្តសម្របសម្រួលអំពីវឌ្ឍនភាព នៃសេចក្តីព្រាងអនុស្សរណៈនៃការយោគយល់គ្នា(MOU) ស្តីពីកិច្ចសហប្រតិបត្តិការប្រយុទ្ធប្រឆាំងគ្រឿងញៀនតាមលម្ហសមុទ្រ រវាងអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ជាមួយកងកម្លាំងឆ្មាំសមុទ្រនៃសាធារណៈរដ្ឋកូរ៉េ។

**៦.៤.** ត្រៀមចូលរួមកិច្ចប្រជុំមន្ត្រីជាន់ខ្ពស់អាស៊ានលើកទី៤៧ ស្តីពីបញ្ហាគ្រឿងញៀន និងកិច្ចប្រជុំពាក់ព័ន្ធ តាមប្រព័ន្ធអនឡាញ។៩

## ៧. ការពង្រឹងយន្តការត្រួតពិនិត្យគ្រឿងញៀននៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ

**៧.១.** បន្តពង្រឹងប្រសិទ្ធភាពក្នុងការអនុវត្តបទបញ្ជាលេខ០១ បប របស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការម៉ឺងម៉ាត់ក្នុងការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់ នៅតាមក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

**៧.២.** បន្តពង្រឹងការអនុវត្តបទបញ្ជាលេខ០២ បប របស់រាជរដ្ឋាភិបាល ស្តីពីការដាក់ចេញវិធានការហាមឃាត់ការនាំចូល ការចែកចាយ ការលក់ ការផ្សាយពាណិជ្ជកម្ម ការប្រើប្រាស់ ការកាន់កាប់ ការផលិត និងការស្តុកទុកឧបករណ៍អេឡិចត្រូនិកនិងសារធាតុគីមីសម្រាប់ជក់ និងស៊ីស្សា។

**៧.៣.** បន្តជំរុញអនុវត្តផែនការ ស្តីពីយុទ្ធនាការប្រយុទ្ធប្រឆាំងគ្រឿងញៀនខុសច្បាប់លើកទី១១។

**៧.៤.** បន្តសហការជាមួយអគ្គស្នងការដ្ឋាននគរបាលជាតិនៃក្រសួងមហាផ្ទៃ ដើម្បីរៀបចំ និងកែសម្រួលសេចក្តីប្រកាសស្តីពីនីតិវិធីនៃការប្រគល់ដោយមានការឃ្លាំមើល និងការញុះញង់ឱ្យលក់ដោយខុសច្បាប់។

**៧.៥.** ត្រៀមរៀបចំបញ្ចូលសារធាតុញៀន ប៉ះពាល់ប្រព័ន្ធប្រសាទ និងសារធាតុគីមីផ្សំថ្មី ចូលទៅក្នុងឧបសម្ព័ន្ធនៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

**៧.៦.** ត្រៀមបញ្ចប់ដំណើរការ និងរៀបចំលទ្ធផល នៃការអង្កេតស្តីពីការយល់ឃើញរបស់ប្រជាពលរដ្ឋលើបញ្ហាគ្រឿងញៀន នៅរាជធានី ខេត្តទាំង១៣។

**អគ្គលេខាធិការ**

នាយឧត្តមសេនីយ៍ **មាស-វិរិទ្ធ**

**ចម្លងជូន៖**

- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមសន្តិបណ្ឌិត ឧបនាយករដ្ឋមន្ត្រី ប្រធាន អ.ជ.ប.គ.ញ.
  "ដើម្បីគោរពជូនជ្រាប"
- ឯកឧត្តមអនុប្រធាន និងសមាជិក អ.ជ.ប.គ.ញ.
- គណៈកម្មាធិការត្រួតពិនិត្យគ្រឿងញៀនរាជធានី ខេត្ត
- អគ្គលេខាធិការរងនៃអ.ជ.ប.គ.ញ.
- នាយកដ្ឋានសរុប ទីស្តីការគណៈរដ្ឋមន្ត្រី
- នាយកដ្ឋាននិងមន្ទីរពិសោធន៍នៃ អ.ជ.ប.គ.ញ.
  "ដើម្បីមុខការ"
- ឯកសារ កាលប្បវត្តិ